ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# សៀវភៅប្រតិបត្តិគោល

# ស្តីពី

# កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូន

# ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ

ខែកញ្ញា ឆ្នាំ២០១៩

# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជាមានចុក្ខវិស័យវែងឆ្ងាយក្នុងការគាំពារសង្គម ដោយកសាងប្រព័ន្ធគាំពារសង្គម មួយដែលមានប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ ដើម្បីបម្រើដល់គោលនយោបាយកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព តាមរយៈការដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម២០១៦-២០២៥ ដែលផ្តោតលើសសរស្តម្ភចំនួនពីរគឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។

ក្នុងការលើកកម្ពស់ប្រព័ន្ធជំនួយសង្គម រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារតូចអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រ តាមរយៈការលើកទឹកចិត្តស្ត្រី និងកុមារឱ្យប្រើប្រាស់សេវាសុខភាព ដោយភ្ជាប់លក្ខខណ្ឌជាមួយទម្លាប់ថែទាំសុខភាពចាំបាច់មួយចំនួន ក្នុងគោលបំណងលើកកម្ពស់សុខុមាលភាពមាតា និងកុមារ ព្រមទាំងរួមចំណែកដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារក្នុងគ្រួសារក្រីក្រ ចាប់តាំងកូនក្នុងផ្ទៃរហូតដល់អាយុ២ឆ្នាំ ដើម្បីជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានកំណត់ឱ្យដឹកនាំ គ្រប់គ្រង និងអនុវត្តកម្មវិធីនេះ ដោយរួមសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម ព្រមទាំងស្ថាប័នពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ក្នុងការពង្រឹងយន្តការសម្របសម្រួល ដើម្បីធានាបាននូវអភិបាលកិច្ចល្អ។

សៀវភៅប្រតិបត្តិគោលនេះ ត្រូវបានប្រើប្រាស់សម្រាប់ជាមូលដ្ឋានក្នុងការប្រតិបត្តិកម្មវិធី ដោយបង្ហាញលម្អិតអំពីរចនាសម្ព័ន្ធគ្រប់គ្រង និងសម្របសម្រួលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងដំណើរការអនុវត្តកម្មវិធី ដើម្បីធានាបាននូវប្រសិទ្ធភាព និរន្តភាព និងភាពងាយស្រួលក្នុងការអនុវត្ត និងគ្រប់គ្រងកម្មវិធី។

ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា សៀវភៅប្រតិបត្តិគោលនេះ នឹងក្លាយជាឧបករណ៍មួយយ៉ាងសំខាន់ក្នុងការជួយលើកកម្ពស់គុណភាពជីវិតរបស់ស្ត្រីមានផ្ទៃពោះ និងកុមារ ក្នុងគ្រួសារក្រីក្រ ប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ សូមថ្លែងអំណរគុណចំពោះអង្គការយូនីសេហ្វ ដែលបានរួមចំណែកក្នុងការគាំទ្របច្ចេកទេស និងថវិកាសម្រាប់ការរៀបចំសៀវភៅប្រតិបត្តិគោលនេះឡើង។

ថ្ងៃពុធ ៤កើត ខែសាភាម ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែកក្កដា ឆ្នាំ២០១៩

រដ្ឋមន្ត្រី

ទ ស្ទត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ: ៣៧៣ ស.អ.យ.ប្រ.ក

ថ្ងៃពុក្រៃពាច ខែកត្រូបទឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩

# ប្រកាស
# ស្តីពី
# ការដាក់ឲ្យប្រើប្រាស់សៀវភៅប្រតិបត្តិគោលកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូន ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- តាមការចាំបាច់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឲ្យប្រើប្រាស់សៀវភៅប្រតិបត្តិគោលកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រ ដែលចុះថ្ងៃ[illegible] ខែ[illegible]ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី[illegible] ខែ[illegible]ឆ្នាំ២០១៩ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គារលេខ ៧៨៨ មហាវិធីព្រះមុនីវង្ស រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ៧២៦ ០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd, Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

**ប្រការ២.-**

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត រដ្ឋបាលឃុំ សង្កាត់ អាជ្ញាធរដែនដី សមាគម និងអង្គការមិនមែនរាជរដ្ឋាភិបាល អាចប្រើប្រាស់សៀវភៅនេះ ដើម្បីលើកកម្ពស់សុខភាពមាតា និងទារក ព្រមទាំងរួមចំណែកដោះស្រាយបញ្ហា កង្វះអាហារូបត្ថម្ភរបស់កុមារក្នុងគ្រួសារក្រីក្រ ចាប់តាំងកូនក្នុងផ្ទៃរហូតដល់អាយុ ២ឆ្នាំ ដើម្បីជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី ។

**ប្រការ៣.-**

សៀវភៅប្រតិបត្តិគោលឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រ មានសារៈសំខាន់ក្នុងការបែងចែកតួនាទីច្បាស់លាស់ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឲ្យកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រ ប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ធកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានជាតិសង្គមកិច្ច ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត រដ្ឋបាលឃុំ សង្កាត់ អាជ្ញាធរដែនដី សមាគម និងអង្គការមិនមែនរាជរដ្ឋាភិបាល មានភារកិច្ចអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

ទ្ធ សុត

**ចម្លងជូន ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ធកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ក្រសួងសុខាភិបាល
- ក្រុមប្រឹក្សាជាតិគាំពារសង្គម
- គ្រប់សាលារាជធានី ខេត្ត

«ដើម្បីជ្រាប»

- គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងស.អ.យ.
- គ្រប់មន្ទីរ ស.អ.យ. រាជធានី ខេត្ត
- ដូចប្រការ៥ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ

# មាតិកា

**សេចក្តីផ្តើម** ..... ១

## ជំពូកទី១. ដំណើរការនៃការអនុវត្តកម្មវិធី

**១.១. ការចុះឈ្មោះ និងការបើកផ្តល់លើកដំបូង** ..... ២
១.១.១. គោលបំណងនៃការចុះឈ្មោះ ..... ២
១.១.២. លក្ខខណ្ឌនៃការចុះឈ្មោះ ..... ២
១.១.៣. ការចុះឈ្មោះម្តាយដែលជាអ្នកទទួលផល និងការបើកផ្តល់លើកដំបូង ..... ២
១.១.៤. ការចុះឈ្មោះស្ត្រីពេលសម្រាល និងក្រោយសម្រាល ..... ៣
១.១.៥. ការចុះឈ្មោះកុមារដែលម្តាយមិនបានចុះឈ្មោះក្នុងកម្មវិធី និងការបើកផ្តល់លើកដំបូង ..... ៣
១.១.៦. ការចុះឈ្មោះអ្នកទទួលផលនៅតំបន់ដាច់ស្រយាល ..... ៤

**១.២. ការអនុវត្តលក្ខខណ្ឌ និងការបើកផ្តល់** ..... ៤
១.២.១. ដំណាក់កាល និងកាលវិភាគនៃការបើកផ្តល់ ..... ៤
១.២.២. ការអនុវត្តលក្ខខណ្ឌ និងការបើកផ្តល់ ..... ៥

## ជំពូកទី២. ការត្រួតពិនិត្យការអនុវត្តកម្មវិធី

**២.១. ការតាមដានការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពអ្នកទទួលផល** ..... ៧

**២.២. ការផ្ទៀងផ្ទាត់ព័ត៌មាន និងការរៀបចំរបាយការណ៍** ..... ៧
២.២.១. ការផ្ទៀងផ្ទាត់ព័ត៌មាន និងការរៀបចំរបាយការណ៍នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា. ..... ៨
២.២.២. ការផ្ទៀងផ្ទាត់ព័ត៌មាន និងការរៀបចំរបាយការណ៍នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ..... ៩

**២.៣. យន្តការនៃការដោះស្រាយវិវាទ និងបណ្តឹង** ..... ១០
២.៣.១. ការដោះស្រាយវិវាទ និងបណ្តឹងរបស់អ្នកទទួលផល ..... ១០
២.៣.២. ការដោះស្រាយករណីក្លែងបន្លំរបស់អ្នកទទួលផល ..... ១២
២.៣.៣. ការស៊ើបអង្កេតអំពីកំហុសដែលប្រព្រឹត្តដោយមន្ត្រីកម្មវិធី ..... ១៣

**២.៤. ការចាកចេញពីកម្មវិធី** ..... ១៣

**២.៥. ការពិនិត្យតាមដាន និងការវាយតម្លៃកម្មវិធី** ..... ១៤

២.៥.១. ការពិនិត្យតាមដាន ..... ១៥
២.៥.២. ការវាយតម្លៃ ..... ១៧

## ជំពូកទី៣. យន្តការនៃការអនុវត្តកម្មវិធី

**៣.១. ក្រសួង ស្ថាប័នថ្នាក់ជាតិ.....១៩**
៣.១.១. ក្រុមប្រឹក្សាជាតិគាំពារសង្គម .....១៩
៣.១.២. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា .....១៩
៣.១.៣. ក្រសួងមហាផ្ទៃ.....២១
៣.១.៤. ក្រសួងសុខាភិបាល .....២២
៣.១.៥. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ .....២២
៣.១.៦. ក្រសួងផែនការ.....២២
៣.១.៧. ក្រុមការងារបច្ចេកទេសអន្តរក្រសួង .....២៣
**៣.២. អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ..... ២៣**
៣.២.១. រដ្ឋបាលរាជធានី ខេត្ត..... ២៣
៣.២.២. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ..... ២៤
៣.២.៣. មន្ទីរសុខាភិបាលរាជធានី ខេត្ត ..... ២៥
៣.២.៤. មូលដ្ឋានសុខាភិបាលសាធារណៈ..... ២៥
៣.២.៥. រដ្ឋបាលឃុំ សង្កាត់ ..... ២៦
**៣.៣. ស្ថាប័នបើកផ្តល់ ..... ២៧**

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១. ការពន្យល់ពាក្យគន្លឹះ .....២៨
ឧបសម្ព័ន្ធទី២. សង្ខេបដំណើរការកម្មវិធី .....២៩

# សេចក្តីផ្តើម

ក្នុងអំឡុងពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយពេលសម្រាល គឺជាដំណាក់កាលដ៏សំខាន់ក្នុងការថែទាំសុខភាពរបស់មាតា ទារកទើបកើត និងកុមារ។ ក្នុងអំឡុងពេលនេះ ការអនុវត្តទម្លាប់ថែទាំសុខភាពល្អនឹងផ្តល់ផលវិជ្ជមានដល់សុខភាពមាតា ទារក និងកុមារ។ ដើម្បីចូលរួមចំណែកឆ្លើយតបចំពោះបញ្ហាថែទាំសុខភាព និងអាហារូបត្ថម្ភរបស់ស្ត្រីមានផ្ទៃពោះ ម្តាយកំពុងបំបៅកូន និងកុមារ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ ស្របតាមក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥។

ការដឹកនាំការអនុវត្តកម្មវិធីនេះ ចែកចេញជា ២ ដំណាក់កាល។ ដំណាក់កាលទី១ ជាដំណាក់កាលអន្តរកាល ដែលដឹកនាំ និងអនុវត្តកម្មវិធីដោយក្រសួងសុខាភិបាល និងដំណាក់កាលទី២ ដឹកនាំ និងអនុវត្តកម្មវិធីដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ជាកម្មវិធីជំនួយសង្គមដែលមានភ្ជាប់លក្ខខណ្ឌ ដោយតម្រូវឱ្យអ្នកទទួលផលមកទទួលសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាលសាធារណៈ តាមពេលវេលាកំណត់សម្រាប់ការថែទាំផ្ទៃពោះ ពេលសម្រាល និងក្រោយពេលសម្រាល។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដឹកនាំរៀបចំយន្តការការងារសម្រាប់បន្តអនុវត្តកម្មវិធី ដោយមានការចូលរួមគាំទ្រការអនុវត្តពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេស មូលដ្ឋានសុខាភិបាលសាធារណៈ ដែលមានតួនាទីបន្តការទទួលខុសត្រូវលើការបញ្ជាក់ការអនុវត្តលក្ខខណ្ឌរបស់អ្នកទទួលផលនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ មានគោលបំណងលើកកម្ពស់សុខុមាលភាពមាតា និងទារក ព្រមទាំងរួមចំណែកដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារក្នុងគ្រួសារក្រីក្រ ចាប់តាំងកូនក្នុងផ្ទៃរហូតដល់អាយុ២ឆ្នាំ ដើម្បីជំរុញការលូតលាស់ ទាំងកាយ សម្បទា និងបញ្ញាស្មារតី។

សៀវភៅប្រតិបត្តិគោលនេះ គឺជាឯកសារដែលផ្តល់ការណែនាំលម្អិតអំពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។ សៀវភៅប្រតិបត្តិគោលនេះ ចែកចេញជា ៣ជំពូក ៖

**ជំពូកទី១. ដំណើរការនៃការអនុវត្តកម្មវិធី**

ជំពូកនេះ បង្ហាញអំពីលក្ខខណ្ឌនៃការចុះឈ្មោះ ដំណើរការនៃការចុះឈ្មោះ ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព និងការបើកផ្តល់ ដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់ពីកម្មវិធី។

**ជំពូកទី២. ការពិនិត្យតាមដានការអនុវត្តកម្មវិធី**

ជំពូកនេះ បង្ហាញអំពីដំណើរការនៃការតាមដានការអនុវត្តលក្ខខណ្ឌ ការដោះស្រាយបណ្តឹង ការពិនិត្យតាមដាន និងការវាយតម្លៃ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី។

**ជំពូកទី៣. យន្តការនៃការអនុវត្តកម្មវិធី**

ជំពូកនេះ បង្ហាញអំពីតួនាទី ភារកិច្ចរបស់អង្គភាពអនុវត្ត និងស្ថាប័នគាំទ្រ ក្នុងការពង្រឹងយន្តការសម្របសម្រួលការគ្រប់គ្រង និងការអនុវត្តកម្មវិធី។

# ជំពូកទី១
# ដំណើរការនៃការអនុវត្តកម្មវិធី

## ១.១. ការចុះឈ្មោះ និងការបើកផ្តល់លើកដំបូង

### ១.១.១. គោលបំណងនៃការចុះឈ្មោះ

គោលបំណងនៃការចុះឈ្មោះ គឺផ្តល់លទ្ធភាពឱ្យស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដែលបំពេញតាមលក្ខខណ្ឌ អាចចុះឈ្មោះចូលក្នុងកម្មវិធី ដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់។ ការចុះឈ្មោះធ្វើឡើងជាប្រចាំ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។

### ១.១.២. លក្ខខណ្ឌនៃការចុះឈ្មោះ

ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ត្រូវចុះឈ្មោះក្នុងកម្មវិធី នៅសាលាឃុំ សង្កាត់ណាមួយ។ ដើម្បីអាចចុះឈ្មោះបាន ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ត្រូវបំពេញលក្ខខណ្ឌ និងភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម ៖

**ក). ករណីស្ត្រីមានផ្ទៃពោះ**

- បានពិនិត្យផ្ទៃពោះនៅមូលដ្ឋានសុខាភិបាលសាធារណៈយ៉ាងតិច១ដង ដោយមានភ្ជាប់មកជាមួយនូវសៀវភៅសុខភាពមាតា និង
- ត្រូវមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព

**ខ). ករណីកុមារអាយុក្រោម២ឆ្នាំ**

- ត្រូវមានប័ណ្ណសុខភាពកុមារ( សម្រាប់កុមារដែលម្តាយបានចុះឈ្មោះចូលក្នុងកម្មវិធីរួចកុមារនោះត្រូវបានចុះឈ្មោះជាស្វ័យប្រវត្តិ)
- ត្រូវមានប័ណ្ណសុខភាពកុមារ និងប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាពរបស់គ្រួសារកុមារ (សម្រាប់កុមារដែលម្តាយមិនបានចុះឈ្មោះក្នុងកម្មវិធី)

### ១.១.៣. ការចុះឈ្មោះម្តាយដែលជាអ្នកទទួលផល និងការបើកផ្តល់លើកដំបូង

មេឃុំ ចៅសង្កាត់ ចាត់តាំងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ឬ ចៅសង្កាត់រង ឬ ជំទប់ ឬស្មៀនឃុំ សង្កាត់ ឬបុគ្គលិករបស់ខ្លួនណាម្នាក់ ជាអ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ឱ្យទទួលខុសត្រូវក្នុងការចុះឈ្មោះអ្នកទទួលផល។

ការចុះឈ្មោះ និងការបើកផ្តល់លើកដំបូងត្រូវអនុវត្ត ដូចខាងក្រោម ៖

- បញ្ចូលព័ត៌មានម្តាយជាអ្នកទទួលផល ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- បញ្ចូលព័ត៌មាននៃការអនុវត្តលក្ខខណ្ឌចុងក្រោយគេនៅលើសៀវភៅសុខភាពមាតា ឬប័ណ្ណសុខភាពកុមារ ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- បញ្ចូលព័ត៌មានអំពីប័ណ្ណគណនីធនាគារទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន

- ថតរូបអ្នកទទួលផល និងថតសំណៅឯកសារសម្រាប់ការចុះឈ្មោះ និងប័ណ្ណគណនីធនាគារចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ និងសំណៅឯកសារនៃការចុះឈ្មោះរបស់អ្នកទទួលផលឱ្យបានត្រឹមត្រូវ ដើម្បីអនុម័តការបើកផ្តល់លើកដំបូង។ ក្នុងករណីដែលទិន្នន័យមិនទាន់គ្រប់គ្រាន់ ឬខុសឆ្គង មេឃុំ ចៅសង្កាត់ត្រូវណែនាំអ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ឱ្យកែតម្រូវឡើងវិញ
- ផ្តល់ប័ណ្ណគណនីធនាគារដល់អ្នកទទួលផល និងណែនាំការប្រើប្រាស់ប័ណ្ណគណនីធនាគារ ការថែរក្សា លេខសម្ងាត់ ការបើកផ្តល់ និងទីតាំងបើកផ្តល់
- ស្ថាប័នបើកផ្តល់ ត្រូវផ្ទេរសាច់ប្រាក់ភ្លាមៗ ទៅក្នុងគណនីធនាគាររបស់អ្នកទទួលផល
- អ្នកទទួលផលអាចទៅដកប្រាក់ពីភ្នាក់ងារបើកផ្តល់នៅគ្រប់ទីកន្លែងនៅទូទាំងប្រទេស។

## ១.១.៤. ការចុះឈ្មោះស្ត្រីពេលសម្រាល និងក្រោយសម្រាល

ស្ត្រីចុះឈ្មោះនៅពេលសម្រាលកូន ឬក្រោយសម្រាល២សប្តាហ៍ ព័ត៌មាននៃការអនុវត្តលក្ខខណ្ឌនៃការសម្រាលកូន ឬពិនិត្យក្រោយសម្រាលលើកទី១ (ថ្ងៃទី៧ក្រោយសម្រាល) ឬពិនិត្យក្រោយសម្រាលលើកទី២(ថ្ងៃទី១៤ក្រោយសម្រាល) ត្រូវកត់ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានតាមការអនុវត្តលក្ខខណ្ឌជាក់ស្តែង និងផ្តល់ការបើកផ្តល់។ ការលើកលែងនេះ ផ្តល់ឱកាសឱ្យស្ត្រីសម្រាលកូនមានពេលវេលាគ្រប់គ្រាន់ក្នុងការចុះឈ្មោះ និងមិនបាត់បង់ផលប្រយោជន៍ដែលទទួលបានពីកម្មវិធី។

ដំណើរការនៃការចុះឈ្មោះ និងការបើកផ្តល់លើកដំបូង សម្រាប់ករណីស្ត្រីចុះឈ្មោះនៅពេលសម្រាលកូន ឬក្រោយសម្រាល២សប្តាហ៍ ត្រូវអនុវត្តដូចក្នុងចំណុច ១.១.៣. ការចុះឈ្មោះម្តាយដែលជាអ្នកទទួលផល និងការបើកផ្តល់លើកដំបូង។

## ១.១.៥. ការចុះឈ្មោះកុមារដែលម្តាយមិនបានចុះឈ្មោះក្នុងកម្មវិធី និងការបើកផ្តល់លើកដំបូង

ចំពោះកុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រ ដែលម្តាយមិនបានចុះឈ្មោះចូលក្នុងកម្មវិធី ក៏អាចចុះឈ្មោះចូលក្នុងកម្មវិធីបានផងដែរ។ ចំពោះកុមារ ដែលជាកូនភ្លោះ ត្រូវចុះឈ្មោះជាអ្នកទទួលផលទាំងអស់។ អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវទទួលខុសត្រូវក្នុងការចុះឈ្មោះ ដូចខាងក្រោម ៖

- បញ្ចូលព័ត៌មានកុមារដែលជាអ្នកទទួលផលចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- បញ្ចូលព័ត៌មាននៃការអនុវត្តលក្ខខណ្ឌចុងក្រោយគេនៅលើប័ណ្ណសុខភាពកុមារចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- បញ្ចូលព័ត៌មានអំពីប័ណ្ណគណនីធនាគារទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ថតរូបកុមារដែលជាអ្នកទទួលផល និងថតសំណៅឯកសារសម្រាប់ការចុះឈ្មោះ និងប័ណ្ណគណនីធនាគារចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ និងសំណៅឯកសារនៃការចុះឈ្មោះរបស់អ្នកទទួលផលឱ្យបានត្រឹមត្រូវ ដើម្បីអនុម័តការបើកផ្តល់លើកដំបូង។ ក្នុងករណីដែលទិន្នន័យ

មិនទាន់គ្រប់គ្រាន់ ឬខុសឆ្គង មេឃុំ ចៅសង្កាត់ត្រូវណែនាំអ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ឱ្យកែតម្រូវឡើងវិញ

- ផ្តល់ប័ណ្ណគណនីធនាគារដល់ម្តាយ(ករណីដែលកុមារមានម្តាយ) ឬ ឪពុក ឬអាណាព្យាបាលរបស់កុមារ(ករណីដែលកុមារមិនមានម្តាយ ឬមិននៅជាមួយម្តាយ) និងណែនាំការប្រើប្រាស់ប័ណ្ណគណនីធនាគារ ការថែរក្សា លេខសម្ងាត់ ការបើកផ្តល់ និងទីតាំងបើកផ្តល់
- ស្ថាប័នបើកផ្តល់ត្រូវផ្ទេរសាច់ប្រាក់ភ្លាមៗទៅក្នុងគណនីធនាគាររបស់អ្នកទទួលផល
- អ្នកទទួលផលអាចទៅដកប្រាក់ពីភ្នាក់ងារបើកផ្តល់នៅគ្រប់ទីកន្លែងនៅទូទាំងប្រទេស។

## ១.១.៦. ការចុះឈ្មោះអ្នកទទួលផលនៅតំបន់ដាច់ស្រយាល

ការចុះឈ្មោះស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រ នៅតំបន់ដាច់ស្រយាលដែលមានចម្ងាយពីសាលាឃុំ សង្កាត់លើសពី២០គីឡូម៉ែត្រ អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវចុះទៅដល់ភូមិរបស់ក្រុមគោលដៅ ដើម្បីធ្វើការចុះឈ្មោះចូលក្នុងកម្មវិធី។ ដំណើរការនៃចុះឈ្មោះមានដូចខាងក្រោម ៖

- មេភូមិត្រូវផ្តល់ព័ត៌មានជូនស្ត្រីមានផ្ទៃពោះ និងម្តាយ ឪពុក ឬអាណាព្យាបាលរបស់កុមារអាយុក្រោម ២ឆ្នាំ ក្នុងគ្រួសារក្រីក្រអំពីកម្មវិធី និងតម្រូវការឯកសារនានាសម្រាប់ការចុះឈ្មោះ
- មេភូមិត្រូវផ្តល់ព័ត៌មានដល់អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់អំពីចំនួនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រ ដែលមានលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការចុះឈ្មោះ
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ពិភាក្សាជាមួយមេភូមិ ដើម្បីកំណត់ពេលវេលា និងទីកន្លែងសម្រាប់ការចុះឈ្មោះ
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ រៀបចំកាលវិភាគជាមួយមេភូមិ ដើម្បីចុះឈ្មោះតាមភូមិ
- មេភូមិផ្តល់ព័ត៌មានដល់ស្ត្រីមានផ្ទៃពោះ និងម្តាយ ឪពុក ឬអាណាព្យាបាលរបស់កុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រ ដែលមានលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការចុះឈ្មោះ ដើម្បីមកចុះឈ្មោះ តាមកាលវិភាគកំណត់
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ត្រូវធ្វើការចុះឈ្មោះ តាមដំណើរការ ដូចក្នុងចំណុច ១.១.៣.ការចុះឈ្មោះម្តាយដែលជាអ្នកទទួលផល និងការបើកផ្តល់លើកដំបូង ឬ ១.១.៤. ការចុះឈ្មោះស្ត្រីពេលសម្រាល និងក្រោយសម្រាល ឬចំណុច១.១.៥.ការចុះឈ្មោះកុមារដែលម្តាយមិនបានចុះឈ្មោះក្នុងកម្មវិធី និងការបើកផ្តល់លើកដំបូង។

## ១.២. ការអនុវត្តលក្ខខណ្ឌ និងការបើកផ្តល់

## ១.២.១. ដំណាក់កាល និងកាលវិភាគនៃការបើកផ្តល់

បន្ទាប់ពីបានចុះឈ្មោះចូលក្នុងកម្មវិធី អ្នកទទួលផលត្រូវអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព ដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់តាមដំណាក់កាល ដូចខាងក្រោម ៖

ដំណាក់កាលទី១ ៖ ផ្តល់ការឧបត្ថម្ភចំនួន ៤០ ០០០ រៀល ក្នុង១ដង សម្រាប់ការមកទទួលសេវាពិនិត្យផ្ទៃពោះ ដែលផ្តល់ជាអតិបរមាចំនួន៤ដង មុនពេលសម្រាលកូន

ដំណាក់កាលទី២ ៖ ផ្តល់ការឧបត្ថម្ភចំនួន ២០០ ០០០ រៀល តែ១ដងគត់ នៅពេលសម្រាលកូន

ដំណាក់កាលទី៣ ៖ ផ្តល់ការឧបត្ថម្ភចំនួន ៤០ ០០០រៀល ក្នុង១ដង ដែលផ្តល់ជាអតិបរមាចំនួន ១០ដង ក្នុងនោះ ៣ដង នៅពេលមកទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាលកូន និង៧ដងនៅពេលយកកូនមកទទួលថ្នាំបង្ការរហូតដល់អាយុ២ឆ្នាំ។

ដើម្បីទទួលបានការបើកផ្តល់ ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រត្រូវអនុវត្តតាមលក្ខខណ្ឌពិនិត្យសុខភាព តាមកាលវិភាគ ដូចខាងក្រោម ៖

| ដំណាក់កាល | សេវាពិនិត្យសុខភាព | ពេលវេលាទទួលសេវា |
|---|---|---|
| ដំណាក់កាលទី១ | ការពិនិត្យផ្ទៃពោះលើកទី១ | គភ៌មានអាយុតិចជាង១២សប្តាហ៍ |
| | ការពិនិត្យផ្ទៃពោះលើកទី២ | គភ៌មានអាយុ២០ទៅ២៤សប្តាហ៍ |
| | ការពិនិត្យផ្ទៃពោះលើកទី៣ | គភ៌មានអាយុ៣០ទៅ៣២សប្តាហ៍ |
| | ការពិនិត្យផ្ទៃពោះលើកទី៤ | គភ៌មានអាយុ៣៦ទៅ៣៨សប្តាហ៍ |
| ដំណាក់កាលទី២ | សម្រាលកូន | តាមកាលវេលាជាក់ស្តែង |
| ដំណាក់កាលទី៣ | ការពិនិត្យក្រោយសម្រាលលើកទី១(ពិនិត្យទាំងម្តាយទាំងកូន) | ថ្ងៃទី៧ ក្រោយសម្រាល |
| | ការពិនិត្យក្រោយសម្រាលលើកទី២(ពិនិត្យទាំងម្តាយទាំងកូន) | ថ្ងៃទី១៤ ក្រោយសម្រាល |
| | ការពិនិត្យក្រោយសម្រាលលើកទី៣(ពិនិត្យទាំងម្តាយទាំងកូន) | កូនមានអាយុ១ខែកន្លះ |
| | ការពិនិត្យក្រោយសម្រាលលើកទី៤(ពិនិត្យសុខភាពកូន) | កូនមានអាយុ២ខែកន្លះ |
| | ការពិនិត្យក្រោយសម្រាលលើកទី៥(ពិនិត្យសុខភាពកូន) | កូនមានអាយុ៣ខែកន្លះ |
| | ការពិនិត្យក្រោយសម្រាលលើកទី៦(ពិនិត្យសុខភាពកូន) | កូនមានអាយុ៦ខែ |
| | ការពិនិត្យក្រោយសម្រាលលើកទី៧(ពិនិត្យសុខភាពកូន) | កូនមានអាយុ៩ខែ |
| | ការពិនិត្យក្រោយសម្រាលលើកទី៨(ពិនិត្យសុខភាពកូន) | កូនមានអាយុ១២ខែ |
| | ការពិនិត្យក្រោយសម្រាលលើកទី៩(ពិនិត្យសុខភាពកូន) | កូនមានអាយុ១៨ខែ |
| | ការពិនិត្យក្រោយសម្រាលលើកទី១០(ពិនិត្យសុខភាពកូន) | កូនមានអាយុ២៤ខែ |

## ១.២.២. ការអនុវត្តលក្ខខណ្ឌ និងការបើកផ្តល់

ក្រោយពីទទួលបានការចុះឈ្មោះចូលក្នុងកម្មវិធី និងទទួលបានការឧបត្ថម្ភសាច់ប្រាក់លើកដំបូងរួច អ្នកទទួលផលត្រូវបន្តអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពតាមកាលវិភាគកំណត់ ដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់។ ករណីខកខានអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពតាមកាលវិភាគកំណត់ អ្នកទទួលផលមិនទទួលបានការឧបត្ថម្ភសាច់ប្រាក់ក្នុងលក្ខខណ្ឌពិនិត្យសុខភាពនោះឡើយ លើកលែងតែ ករណីការចុះ

ឈ្មោះស្ត្រីនៅពេលសម្រាល និងក្នុងអំឡុងពេលក្រោយ១៤ថ្ងៃ ក្រោយសម្រាល ដូចមានចែងក្នុងចំណុច ១.១.៤។ ចំពោះកុមារដែលជាកូនភ្លោះរបស់ស្ត្រីដែលបានចុះឈ្មោះក្នុងកម្មវិធីនឹងទទួលបានការឧបត្ថម្ភ សាច់ប្រាក់ទាំងអស់ រហូតដល់អាយុ២ឆ្នាំ។

ឃុំ សង្កាត់ មូលដ្ឋានសុខាភិបាលសាធារណៈ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលបានព័ត៌មាននៃការអនុវត្ត លក្ខខណ្ឌពិនិត្យសុខភាព និងដំណើរការនៃការបើកផ្តល់ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានដោយ ស្វ័យប្រវត្តិ។ ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព និងដំណើរការនៃការបើកផ្តល់មានដូចខាងក្រោម ៖

- អ្នកទទួលផលត្រូវទៅមូលដ្ឋានសុខាភិបាលសាធារណៈណាមួយ ដើម្បីទទួលសេវាពិនិត្យ សុខភាពតាមកាលវិភាគ ដោយយកមកជាមួយសៀវភៅសុខភាពមាតា ឬប័ណ្ណសុខភាពកុមារ និងប័ណ្ណគណនីធនាគារ
- បុគ្គលិកមូលដ្ឋានសុខាភិបាលសាធារណៈត្រូវបញ្ជាក់ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព ក្នុង ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន រួចបញ្ជូនទៅក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិ សម្បទា
- ក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទាបញ្ជូនព័ត៌មាននៃការអនុវត្តលក្ខខណ្ឌតាម ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានទៅស្ថាប័នបើកផ្តល់
- ស្ថាប័នបើកផ្តល់ផ្ទេរសាច់ប្រាក់ភ្លាមៗទៅក្នុងគណនីធនាគាររបស់អ្នកទទួលផល
- អ្នកទទួលផលអាចទៅដកប្រាក់ពីភ្នាក់ងារបើកផ្តល់នៅគ្រប់ទីកន្លែងនៅទូទាំងប្រទេស។

# ជំពូកទី២
# ការត្រួតពិនិត្យការអនុវត្តកម្មវិធី

## ២.១. ការតាមដានការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពអ្នកទទួលផល

ឃុំ សង្កាត់ ត្រូវទទួលខុសត្រូវក្នុងការពិនិត្យតាមដានការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពរបស់អ្នកទទួលផលតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ដើម្បីជំរុញអ្នកទទួលផលឱ្យអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពឱ្យបានទៀងទាត់។ ការតាមដានការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពរបស់អ្នកទទួលផលនៅថ្នាក់ឃុំ សង្កាត់ ដំណើរការតាមជំហានដូចខាងក្រោម ៖

- បន្ទាប់ពីទទួលបានព័ត៌មានអំពីការខកខានៃការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព២ដងជាប់គ្នារបស់អ្នកទទួលផលក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន មេឃុំ ចៅសង្កាត់ត្រូវលើកយកបញ្ហានោះដាក់ទៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- ផ្អែកតាមលទ្ធផលកិច្ចប្រជុំ អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ត្រូវបញ្ជាក់ក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ដើម្បីដំណើរការតាមដានការខកខានអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវសហការជាមួយមេភូមិចុះប្រមូលព័ត៌មានអំពីមូលហេតុនៃការខកខានក្នុងការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព មិនឱ្យហួសពី២សប្តាហ៍បន្ទាប់ពីកិច្ចប្រជុំ ដើម្បីស្វែងរកដំណោះស្រាយ និងជំរុញអ្នកទទួលផលឱ្យអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពឡើងវិញ
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវរាយការណ៍ពីសកម្មភាព និងលទ្ធផលនៃការតាមដានការខកខានៃការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពជូនគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងកិច្ចប្រជុំបន្ទាប់
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវបញ្ចូលលទ្ធផលនៃការតាមដានការខកខានៃការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវបិទការតាមដានការខកខានៃការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន នៅពេលដែលអ្នកទទួលផលត្រឡប់មកអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពឡើងវិញ។

## ២.២. ការផ្ទៀងផ្ទាត់ព័ត៌មាន និងការរៀបចំរបាយការណ៍

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដើម្បីដាក់ជូនក្រុមការងារបច្ចេកទេសអន្តរក្រសួង និងក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ២.២.១. ការផ្ទៀងផ្ទាត់ព័ត៌មាន និងការរៀបចំរបាយការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ការផ្ទៀងផ្ទាត់ព័ត៌មាន និងការរៀបចំរបាយការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តដោយក្រុមការងារ ដូចខាងក្រោម៖

**ក). ក្រុមការងារប្រតិបត្តិកម្មវិធី**

- ពិនិត្យ និងផ្ទៀងផ្ទាត់របាយការណ៍ប្រតិបត្តិការប្រចាំថ្ងៃអំពីការចុះឈ្មោះ អនុវត្តលក្ខខណ្ឌពិនិត្យសុខភាព និងការបើកផ្តល់ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- តាមដានព័ត៌មានអំពីបញ្ហាដែលបានកើតឡើងពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី នៅលើបណ្តាញសង្គម និងសារព័ត៌មាននានា ដើម្បីដោះស្រាយ
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធី ដែលបង្ហាញអំពីអ្នកទទួលផល និងការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព ដោះស្រាយពាក្យបណ្តឹងតវ៉ា ករណីក្លែងបន្លំ និងការប្រព្រឹត្តមិនត្រឹមត្រូវរបស់មន្ត្រី។

**ខ). ក្រុមការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយ**

- រៀបចំទិន្នន័យបណ្តុះបណ្តាល និងការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង
- រៀបចំរបាយការណ៍បណ្តុះបណ្តាល ការផ្សព្វផ្សាយ និងសកម្មភាពបង្កើនការយល់ដឹងផ្សេងៗទៀត។

**គ). ក្រុមការងារគ្រប់គ្រងប្រព័ន្ធព័ត៌មាន**

- ផ្តល់ទិន្នន័យអំពីចំនួនអ្នកទទួលផល បណ្តឹងតវ៉ា ការគ្រប់គ្រងករណី និងការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព ដល់ក្រុមការងារប្រតិបត្តិកម្មវិធី
- បោះពុម្ពរបាយការណ៍ប្រតិបត្តិការប្រចាំថ្ងៃរបស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ទាញយកទិន្នន័យប្រតិបត្តិការប្រចាំថ្ងៃពីប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ដើម្បីរក្សាទុក
- រាយការណ៍អំពីភាពអាក់អន្ធ និងតម្រូវឱ្យជួសជុលថែទាំសម្រាប់ដំណើរការរបស់ប្រព័ន្ធ។

**ឃ). ក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុ**

- រៀបចំសំណើសុំថវិកា ការកែសម្រួល ការព្យាករណ៍ចំណាយរំពឹងទុក
- រៀបចំរបាយការណ៍ទូទាត់ និងការផ្ទេរសាច់ប្រាក់ពីរតនាគារជាតិ
- របាយការណ៍តាមដានការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព និងផ្ទៀងផ្ទាត់ការទូទាត់ជាមួយស្ថាប័នបើកផ្តល់
- បូកសរុប និងរៀបចំរបាយការណ៍ផ្ទៀងផ្ទាត់ហិរញ្ញវត្ថុ។

## ២.២.២. ការផ្ទៀងផ្ទាត់ព័ត៌មាន និងការរៀបចំរបាយការណ៍របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត

ការផ្ទៀងផ្ទាត់ព័ត៌មាន និងការរៀបចំរបាយការណ៍របស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវអនុវត្តដោយមន្ត្រីទទួលបន្ទុក ដូចខាងក្រោម៖

**ក). មន្ត្រីប្រតិបត្តិកម្មវិធី**

- ផ្ទៀងផ្ទាត់របាយការណ៍ប្រតិបត្តិការប្រចាំថ្ងៃអំពីការចុះឈ្មោះ អនុវត្តលក្ខខណ្ឌពិនិត្យសុខភាព និងការបើកផ្តល់ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- តាមដានព័ត៌មានអំពីបញ្ហា ដែលបានកើតឡើងពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី នៅលើបណ្តាញសង្គម និងសារព័ត៌មាននានា ដើម្បីដោះស្រាយ
- រាយការណ៍ជាបន្ទាន់នូវរាល់បញ្ហាដែលមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត មិនអាចដោះស្រាយបាន មកក្រុមការងារប្រតិបត្តិកម្មវិធីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធី ដែលបង្ហាញអំពីអ្នកទទួលផល និងការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព ដោះស្រាយពាក្យបណ្តឹងតវ៉ា ករណីក្លែងបន្លំ និងការប្រព្រឹត្តមិនត្រឹមត្រូវរបស់មន្ត្រី។

**ខ). មន្ត្រីបណ្តុះបណ្តាល និងគ្រប់គ្រងប្រព័ន្ធព័ត៌មាន**

- រៀបចំទិន្នន័យបណ្តុះបណ្តាល និងការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង
- រៀបចំរបាយការណ៍បណ្តុះបណ្តាល ការផ្សព្វផ្សាយ និងសកម្មភាពបង្កើនការយល់ដឹងផ្សេងៗទៀត
- ផ្តល់ទិន្នន័យពាក់ព័ន្ធនឹងចំនួនអ្នកទទួលផល បណ្តឹងតវ៉ា ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព និងការតាមដានការអនុវត្តលក្ខខណ្ឌទៅមន្ត្រីប្រតិបត្តិកម្មវិធី
- បោះពុម្ពរបាយការណ៍ប្រតិបត្តិការប្រចាំថ្ងៃរបស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- រាយការណ៍ពីការគាំទ្របច្ចេកទេស និងការដោះស្រាយបញ្ហាក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាននៅឃុំ សង្កាត់។

**គ). មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ**

- បូកសរុប និងរៀបចំរបាយការណ៍ផ្ទៀងផ្ទាត់ហិរញ្ញវត្ថុ
- របាយការណ៍តាមដានការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព និងផ្ទៀងផ្ទាត់ការទូទាត់ជាមួយស្ថាប័នបើកផ្តល់។

## ២.៣. យន្តការនៃការដោះស្រាយវិវាទ និងបណ្តឹង

### ២.៣.១. ការដោះស្រាយវិវាទ និងបណ្តឹងរបស់អ្នកទទួលផល

ការដោះស្រាយវិវាទមានគោលបំណងផ្តល់ឱកាសឱ្យអ្នកទទួលផលលើកយកវិវាទនានាពាក់ព័ន្ធនឹងការចុះឈ្មោះ ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព និងការបើកផ្តល់ ដើម្បីឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីអាចចូលរួមដោះស្រាយ។

ឃុំ សង្កាត់ទទួលខុសត្រូវបញ្ជូលការប្តឹងតវ៉ា និងដំណោះស្រាយ ព្រមទាំងធ្វើបច្ចុប្បន្នភាព និងតាមដានដំណោះស្រាយទាំងនោះទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ ការទទួល និងដោះស្រាយបណ្តឹងតវ៉ាមានដំណើរការ ដូចខាងក្រោម ៖

**ក. វិវាទកើតឡើងក្នុងអំឡុងពេលចុះឈ្មោះ**

- អ្នកទទួលផលអាចប្តឹងតវ៉ា ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរទៅឃុំ សង្កាត់ដោយផ្ទាល់ ឬតាមរយៈមេភូមិ។
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ត្រូវបញ្ជូលព័ត៌មានអំពីការប្តឹងតវ៉ាទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ហើយត្រូវធ្វើការដោះស្រាយភ្លាមៗ។
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវពិនិត្យមើលបណ្តឹងតវ៉ាដែលមិនអាចដោះស្រាយដាក់ទៅក្នុងកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីដោះស្រាយ។
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ត្រូវតាមដាន និងដោះស្រាយភ្លាមៗ បន្ទាប់ពីកិច្ចប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ រួចបញ្ជូលលទ្ធផលដំណោះស្រាយទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។
- ពាក្យបណ្តឹងតវ៉ាណាពុំអាចដោះស្រាយបាននៅកម្រិតឃុំ សង្កាត់ត្រូវបញ្ជូនទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្តតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវពិនិត្យមើលវិវាទទាំងនោះក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន និងសហការជាមួយអ្នកពាក់ព័ន្ធ ដើម្បីធ្វើការដោះស្រាយឱ្យបានទាន់ពេលវេលា រួចបញ្ជូលលទ្ធផលដំណោះស្រាយទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។
- ករណី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត មិនអាចដោះស្រាយបញ្ហាទាំងនោះបាន ត្រូវរាយការណ៍មកក្រុមការងារប្រតិបត្តិក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិនិត្យ និងដោះស្រាយ។
- ករណីក្រុមការងារប្រតិបត្តិក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មិនអាចដោះស្រាយបានត្រូវរាយការណ៍មកអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីពិនិត្យ និងដោះស្រាយ។

- ករណីអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម មិនអាចដោះស្រាយបាន អ្នកប្តឹងតវ៉ាអាចរៀបចំបណ្តឹងតវ៉ាស្របតាមនីតិវិធីច្បាប់ ដើម្បីបញ្ជូនទៅតុលាការ។
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវជូនដំណឹងដល់អ្នកទទួលផល តាមរយៈមេភូមិ បន្ទាប់ពីវិវាទត្រូវបានដោះស្រាយរួច។

**ខ. វិវាទកើតឡើងក្នុងការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព និងវិវាទកើតឡើងក្នុងការបើកផ្តល់**

- អ្នកទទួលផលអាចប្តឹងតវ៉ា ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរទៅឃុំ សង្កាត់ដោយផ្ទាល់ ឬតាមរយៈមេភូមិ។
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ត្រូវបញ្ចូលព័ត៌មានអំពីការប្តឹងតវ៉ាទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ហើយត្រូវធ្វើការដោះស្រាយភ្លាមៗ។
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវពិនិត្យមើលបណ្តឹងតវ៉ាដែលមិនអាចដោះស្រាយដាក់ទៅក្នុងកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីដោះស្រាយ។
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ត្រូវតាមដាន និងដោះស្រាយភ្លាមៗ បន្ទាប់ពីកិច្ចប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ រួចបញ្ចូលលទ្ធផលដំណោះស្រាយទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។
- ពាក្យបណ្តឹងតវ៉ាណាពុំអាចដោះស្រាយបាននៅកម្រិតឃុំ សង្កាត់ ត្រូវបញ្ជូនទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្តតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវពិនិត្យមើលបណ្តឹងតវ៉ាទាំងនោះ ក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន និងសហការជាមួយអ្នកពាក់ព័ន្ធ ដើម្បីធ្វើការដោះស្រាយឱ្យបានទាន់ពេលវេលា រួចបញ្ចូលលទ្ធផលដំណោះស្រាយទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។
- ករណី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត មិនអាចដោះស្រាយវិវាទទាំងនោះបាន ត្រូវរាយការណ៍មកក្រុមការងារប្រតិបត្តិក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិនិត្យ និងដោះស្រាយ។
- ករណីក្រុមការងារប្រតិបត្តិក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មិនអាចដោះស្រាយបានត្រូវរាយការណ៍មកអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីពិនិត្យ និងដោះស្រាយ។
- ករណីអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម មិនអាចដោះស្រាយបាន អ្នកប្តឹងតវ៉ាអាចរៀបចំបណ្តឹងតវ៉ាតាមនីតិវិធីច្បាប់បញ្ជូនទៅតុលាការ។
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវជូនដំណឹងដល់អ្នកទទួលផល តាមរយៈមេភូមិ បន្ទាប់ពីវិវាទណាមួយបានដោះស្រាយរួច។

## ២.៣.២. ការដោះស្រាយករណីក្លែងបន្លំរបស់អ្នកទទួលផល

ប្រសិនបើរកឃើញថា អ្នកទទួលផលមានចេតនាក្លែងបន្លំ ក្នុងអំឡុងពេលចុះឈ្មោះ ឬប្រព្រឹត្តការក្លែងបន្លំផ្ទុយនឹងគោលការណ៍របស់កម្មវិធី អ្នកទទួលផលនោះនឹងត្រូវដកចេញពីកម្មវិធី។

ការដោះស្រាយលើករណីផ្តល់ព័ត៌មានក្លែងបន្លំ ត្រូវដំណើរការដូចខាងក្រោម ៖

- ករណីមានការរាយការណ៍ពីភាពមិនប្រក្រតីរបស់អ្នកទទួលផលអំពីការក្លែងបន្លំ អ្នករាយការណ៍នោះត្រូវរាយការណ៍ជូនអ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ដោយភ្ជាប់មកជាមួយនូវកស្តុតាង។
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវពិនិត្យមើលឯកសារដែលបានរាយការណ៍នោះជាបឋម។ ប្រសិនបើ សង្ស័យមានការក្លែងបន្លំ អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ត្រូវបញ្ជូនករណីនេះ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត។
- មន្ត្រីប្រតិបត្តិកម្មវិធីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ធ្វើការស៊ើបអង្កេត ដោយចុះទៅជួបពិភាក្សាជាមួយអ្នកទទួលផលដែលសង្ស័យនោះ និងប្រមូលព័ត៌មានពីបុគ្គលពាក់ព័ន្ធ។ អំឡុងពេលនៃការស៊ើបអង្កេត មន្ត្រីប្រតិបត្តិកម្មវិធីរបស់មន្ទីរ ត្រូវផ្តល់ព័ត៌មានតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្នើសុំផ្អាកការបើកផ្តល់ជាបណ្តោះអាសន្នរបស់អ្នកទទួលផល ។
- បន្ទាប់ពីស៊ើបអង្កេតរួច មន្ត្រីប្រតិបត្តិកម្មវិធីរបស់មន្ទីរត្រូវផ្តល់ព័ត៌មានអំពីលទ្ធផលនៃការស៊ើបអង្កេតដល់ឃុំ សង្កាត់ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ លទ្ធផលស៊ើបអង្កេតនេះ ជាលទ្ធផលស្ថាពរ។
- អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវជួបផ្ទាល់ជាលក្ខណៈបុគ្គលជាមួយអ្នកទទួលផលនោះ ដើម្បីផ្តល់ព័ត៌មានអំពីលទ្ធផលនៃការស៊ើបអង្កេត។ អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ជូនដំណឹងមកក្រសួង ថាបានផ្តល់ព័ត៌មានដល់អ្នកទទួលផលរួចហើយ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។
- បន្ទាប់ពីទទួលបានព័ត៌មានពីឃុំ សង្កាត់ តាម MIS ក្រសួងផ្តល់ការអនុញ្ញាតបើកផ្តល់ឡើងវិញភ្លាមៗតាមតារាងពេលវេលានៃការពិនិត្យសុខភាព ដែលមិនបានបើកផ្តល់ក្នុងអំឡុងពេលស៊ើបអង្កេត ក្នុងករណីដែលមិនមានការក្លែងបន្លំ ឬសម្រេចឱ្យអ្នកទទួលផលចាកចេញពីកម្មវិធី ក្នុងករណីដែលមានការក្លែងបន្លំ។

### ២.៣.៣. ការដោះស្រាយករណីកំហុសប្រព្រឹត្តដោយមន្ត្រីកម្មវិធី

នៅពេលដែលមានការសង្ស័យអំពីការប្រព្រឹត្តមិនប្រក្រតីរបស់មន្ត្រីកម្មវិធី ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

- អ្នកប្តឹងត្រូវដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅឃុំ សង្កាត់ ឬមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ឬក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយដាក់ក្នុងស្រោមសំបុត្របិតជិត។
- បន្ទាប់ពីទទួលបានពាក្យបណ្តឹង ឃុំ សង្កាត់ ត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត។
- បន្ទាប់ពីទទួលបានពាក្យបណ្តឹងពីឃុំ សង្កាត់ ឬអ្នកប្តឹង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្តត្រូវបញ្ជូនពាក្យបណ្តឹងទាំងនោះទៅក្រុមការងារកម្មវិធីជំនួយសង្គមរាជធានី ខេត្ត ដើម្បីប្រជុំដោះស្រាយ។
- ករណីពាក្យបណ្តឹងទាំងនោះមិនអាចដោះស្រាយបាន ក្រុមការងារកម្មវិធីជំនួយសង្គមរាជធានី ខេត្ត ត្រូវបញ្ជូនបណ្តឹងទាំងនោះ ដោយភ្ជាប់មកជាមួយរបាយការណ៍លទ្ធផលប្រជុំអំពីការដោះស្រាយ មកក្រុមការងារប្រតិបត្តិកម្មវិធីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- ក្រុមការងារប្រតិបត្តិកម្មវិធីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងដោះស្រាយបណ្តឹងដែលបញ្ជូនមកពីក្រុមការងារកម្មវិធីជំនួយសង្គមរាជធានី ខេត្ត ឬបណ្តឹងដែលប្តឹងនៅថ្នាក់ក្រសួង។
- ករណីពាក្យបណ្តឹងទាំងនោះ មិនអាចដោះស្រាយបានដោយក្រុមការងារប្រតិបត្តិកម្មវិធីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវរាយការណ៍ជូនក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់ដែលមានជាធរមាន។

## ២.៤. ការចាកចេញពីកម្មវិធី

ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រ ដែលបានចុះឈ្មោះក្នុងកម្មវិធីរួច នឹងបន្តទទួលបានការឧបត្ថម្ភសាច់ប្រាក់ ទោះបីជាគ្រួសាររបស់អ្នកទទួលផលនោះ លែងកំណត់ជាគ្រួសារក្រីក្រ តាមរយៈការធ្វើបច្ចុប្បន្នភាពអត្តសញ្ញាណកម្មគ្រួសារក្រីក្រក៏ដោយ។

អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវពិនិត្យ ផ្ទៀងផ្ទាត់ព័ត៌មាន និងធ្វើបច្ចុប្បន្នភាពជាប្រចាំអំពីឈ្មោះអ្នកទទួលផលដែលបាន និងត្រូវចាកចេញពីកម្មវិធី តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។

ព័ត៌មាននៃការចាកចេញពីកម្មវិធីរបស់អ្នកទទួលផលត្រូវបញ្ជូន តាមរយៈមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត មកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីអនុម័តការចាកចេញពីកម្មវិធី តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។

អ្នកទទួលផលត្រូវចាកចេញពីកម្មវិធី ក្នុងករណី ៖

- **រលូតកូន** ការឧបត្ថម្ភសាច់ប្រាក់ត្រូវបានផ្តល់ជូន ៖
  - ✓ ៤០ ០០០ រៀល តែ ១ដងគត់ ក្នុងករណីគភ៌អាយុក្រោម ១២សប្តាហ៍
  - ✓ ៤០ ០០០ រៀល ក្នុង១ដង ដែលផ្តល់ជាអតិបរមាចំនួន២ដង ក្នុងករណីគភ៌អាយុពី ១២សប្តាហ៍ ដល់២៤សប្តាហ៍។
- **រំលូតកូន** ការឧបត្ថម្ភសាច់ប្រាក់ត្រូវបញ្ឈប់ ហើយអ្នកទទួលផលត្រូវឱ្យចាកចេញពីកម្មវិធី
- **កូនស្លាប់ពេលសម្រាល ឬក្រោយពេលសម្រាល** ការឧបត្ថម្ភសាច់ប្រាក់ត្រូវបន្តផ្តល់ជូន ៖
  - ✓ ២០០ ០០០ រៀល នៅពេលសម្រាល
  - ✓ ៤០ ០០០ រៀល ក្នុង១ដង ដែលផ្តល់ជាអតិបរមាចំនួន៣ដង នៅពេលមកទទួលសេវាពិនិត្យសុខភាពក្រោយពេលសម្រាលកូន។
- **ម្តាយស្លាប់នៅពេលសម្រាល** ការឧបត្ថម្ភសាច់ប្រាក់ត្រូវបន្តផ្តល់ជូនអាណាព្យាបាលស្របច្បាប់ ឬអ្នកដែលមានសិទ្ធិស្របច្បាប់ ឬអ្នកដែលនាំកូនមកទទួលសេវា ៖
  - ✓ ២០០ ០០០រៀល សម្រាប់ការសម្រាល
  - ✓ ៤០ ០០០រៀលក្នុង១ដង ដែលផ្តល់ជាអតិបរមាចំនួន១០ដង នៅពេលយកកូនមកទទួលសេវាថែទាំសុខភាពរហូតដល់កូនអាយុ២ឆ្នាំ។
- **ការចាកចេញដោយស្ម័គ្រចិត្ត** ៖ អ្នកទទួលផលអាចសម្រេចចិត្តចាកចេញពីកម្មវិធី ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់។ អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពឈ្មោះអ្នកទទួលផលតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- **ការក្លែងបន្លំ ៖** អ្នកទទួលផលដែលផ្តល់ព័ត៌មានមិនពិត ឬក្លែងបន្លំត្រូវលុបចេញពីកម្មវិធី ហើយត្រូវបញ្ឈប់ការបើកផ្តល់។ ដំណើរការលុបឈ្មោះអ្នកទទួលផលចេញពីកម្មវិធីនេះ ត្រូវស្ទើបអង្កេតតាមនីតិវិធី ដូចមាននៅក្នុងចំណុច២.៣.២។ ព័ត៌មាននេះត្រូវធ្វើបច្ចុប្បន្នភាពតាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- **កុមារមានអាយុលើសពី២ឆ្នាំ ៖** កុមារដែលបានចុះឈ្មោះក្នុងកម្មវិធី នៅពេលដែលមានអាយុលើសពី២ឆ្នាំ ត្រូវបានចាកចេញពីកម្មវិធីដោយស្វ័យប្រវត្តិនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។

## ២.៥. ការពិនិត្យតាមដាន និងការវាយតម្លៃកម្មវិធី

ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ គឺជាមូលដ្ឋានសម្រាប់ការពិនិត្យតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិធី។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវរៀបចំក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃកម្មវិធី ដោយផ្អែកលើទិន្នន័យដែលបានកត់ត្រាក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន និងបញ្ហាប្រឈមនានា ដែលបានជួបប្រទះនៅក្នុងដំណើរការនៃការអនុវត្តកម្មវិធី។

## ២.៥.១. ការពិនិត្យតាមដាន

ការពិនិត្យតាមដានការអនុវត្តកម្មវិធីត្រូវធ្វើឡើង ដោយផ្អែកលើរបាយការណ៍ទទួលបានពីប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន និងការចុះប្រមូលព័ត៌មាននៅតាមឃុំ សង្កាត់ មូលដ្ឋានសុខាភិបាលសាធារណៈ និងសហគមន៍។ ការពិនិត្យតាមដាន មានដូចខាងក្រោម ៖

### ក). ការពិនិត្យតាមដានរបស់ឃុំ សង្កាត់

អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ត្រូវសហការជាមួយគណៈកម្មាធិការទទួលបន្ទុកកិច្ចនារី និងកុមារឃុំ សង្កាត់ ដើម្បីពិនិត្យតាមដានការអនុវត្តកម្មវិធី ដូចខាងក្រោម ៖

**ការពិនិត្យតាមដានផ្តោតលើ ៖**

- ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រដែលមិនទាន់បានចុះឈ្មោះក្នុងកម្មវិធី
- អ្នកទទួលផលខកខានមិនបានអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពតាមកាលវិភាគពិនិត្យសុខភាព

**ការពិនិត្យតាមដាន ត្រូវធ្វើឡើងដោយ ៖**

- មេភូមិនីមួយៗ រាយការណ៍ពីស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដែលមាននៅក្នុងភូមិដែលមិនទាន់បានចុះឈ្មោះក្នុងកម្មវិធីចូលទៅក្នុងកិច្ចប្រជុំគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីដាក់ចេញផែនការសកម្មភាពផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីកម្មវិធី។
- តាមរបាយការណ៍ក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន អ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ រាយការណ៍ជូនកិច្ចប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់អំពីការខកខានមិនបានអនុវត្តលក្ខខណ្ឌតាមកាលវិភាគពិនិត្យសុខភាពរបស់អ្នកទទួលផល ដើម្បីឱ្យអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងមេភូមិចុះប្រមូលព័ត៌មានអំពីមូលហេតុនៃការខកខានក្នុងការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព ស្វែងរកដំណោះស្រាយ និងជំរុញអ្នកទទួលផលឱ្យអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពឡើងវិញ។

### ខ). ការពិនិត្យតាមដានរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត

មន្ត្រីប្រតិបត្តិកម្មវិធីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ទទួលខុសត្រូវក្នុងការពិនិត្យតាមដានជាប្រចាំនូវការអនុវត្តកម្មវិធីនៅឃុំ សង្កាត់ និងមូលដ្ឋានសុខាភិបាលសាធារណៈ ដើម្បីផ្តល់ការគាំទ្រ និងការកែលម្អការអនុវត្តកម្មវិធីឱ្យមានប្រសិទ្ធភាព។

**ការពិនិត្យតាមដានផ្តោតលើ ៖**

- ដំណើរការនៃការចុះឈ្មោះអ្នកទទួលផលនៅតាមឃុំ សង្កាត់(ផ្ទៀងផ្ទាត់ព័ត៌មានអ្នកទទួលផល ដំណើរការនៃការចុះឈ្មោះ និងបញ្ហាប្រឈមនានា)
- ដំណើរការនៃការបញ្ជាក់ និងការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពរបស់អ្នកទទួលផលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ

- ដំណើរការប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន (ការប្រើប្រាស់តាប្លេត"Tablet"ប្រព័ន្ធអ៊ីនធឺណែត)
- ដំណើរការដោះស្រាយបណ្តឹងតវ៉ា និងការក្លែងបន្លំរបស់អ្នកទទួលផលនៅតាមឃុំ សង្កាត់
- ការដកប្រាក់របស់អ្នកទទួលផល (សេវាបើកផ្តល់ និងបញ្ហាប្រឈម)

**ការពិនិត្យតាមដាន ត្រូវធ្វើឡើងដោយ ៖**

- តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ការចុះប្រមូលព័ត៌មាននៅតាមឃុំ សង្កាត់ មូលដ្ឋានសុខាភិបាលសាធារណៈ និងសហគមន៍
- រៀបចំកិច្ចប្រជុំ តាមការចាំបាច់ជាមួយឃុំ សង្កាត់ ឬមូលដ្ឋានសុខាភិបាលសាធារណៈមួយចំនួន ដើម្បីពិភាក្សាអំពីបញ្ហា និងវិធានការដោះស្រាយ
- រៀបចំប្រព័ន្ធទូរស័ព្ទ ឬបណ្តាញទំនាក់ទំនងសម្រាប់ទំនាក់ទំនងជាមួយឃុំ សង្កាត់ និងមូលដ្ឋានសុខាភិបាលសាធារណៈ ដើម្បីឆ្លើយតបសំណួរ ឬបញ្ហានានា។

**ការប្រើប្រាស់លទ្ធផលនៃពិនិត្យតាមដាន**

- ករណី ពិនិត្យឃើញថា ព័ត៌មានក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានមិនត្រឹមត្រូវ មន្ត្រីប្រតិបត្តិកម្មវិធីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវជូនដំណឹងដល់ឃុំ សង្កាត់ និងមូលដ្ឋានសុខាភិបាលសាធារណៈ ដើម្បីកែតម្រូវឱ្យបានទាន់ពេលវេលា។
- ចុះពិភាក្សាជាមួយឃុំ សង្កាត់ ឬមូលដ្ឋានសុខាភិបាលសាធារណៈ ដើម្បីពិភាក្សាស្វែងរកវិធានការណ៍ដោះស្រាយនូវបញ្ហាដែលកើតមានឡើង ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី
- រាយការណ៍ជូនគណៈកម្មការបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្វែងរកដំណោះស្រាយ សមស្រប និងកែលម្អកម្មវិធី។

## គ). ការពិនិត្យតាមដានរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រុមការងារប្រតិបត្តិកម្មវិធីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលខុសត្រូវក្នុងការពិនិត្យតាមដានជាប្រចាំនូវការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ដើម្បីផ្តល់ការគាំទ្រ និងការកែលម្អការអនុវត្តកម្មវិធីឱ្យមានប្រសិទ្ធភាព។

**ការពិនិត្យតាមដានផ្តោតលើ ៖**

- ដំណើរការ និងការគ្រប់គ្រងនៃកម្មវិធី (ប្រតិបត្តិកម្មវិធី ហិរញ្ញវត្ថុ ការបើកផ្តល់ កិច្ចសហការ និងការកសាងសមត្ថភាព)
- វឌ្ឍនភាពនៃលទ្ធផលគោលដៅប្រចាំឆ្នាំនៃការអនុវត្តកម្មវិធី។

**ការពិនិត្យតាមដាន ត្រូវធ្វើឡើងដោយ ៖**

- ពិនិត្យមើលរបាយការណ៍ តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន

- ការចុះប្រមូលព័ត៌មានរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ការងារ បច្ចេកទេសអន្តរក្រសួង និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- ប្រជុំឆ្លុះបញ្ចាំងការអនុវត្តកម្មវិធីពាក់កណ្តាលឆ្នាំ និងប្រចាំឆ្នាំ។

**ការប្រើប្រាស់លទ្ធផលនៃការពិនិត្យតាមដាន**

- កែលម្អការអនុវត្តកម្មវិធី(បញ្ហាប្រឈមជាអន្តរវិស័យ)ឱ្យកាន់តែមានប្រសិទ្ធភាព
- វាយតម្លៃភាពចាំបាច់នានា ដើម្បីស្នើសុំកែសម្រួលគោលការណ៍ និងនីតិវិធីអនុវត្តកម្មវិធី ពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ២.៥.២. ការវាយតម្លៃ

ការសិក្សាវាយតម្លៃលើកដំបូង ត្រូវរៀបចំនៅក្នុងឆ្នាំទី២នៃការអនុវត្តកម្មវិធី ដើម្បីផ្តល់ធាតុចូលសម្រាប់កែលម្អដំណើរការអនុវត្ត និងយន្តការគាំទ្រការអនុវត្តកម្មវិធី។

ការវាយតម្លៃពីផលប៉ះពាល់របស់កម្មវិធីត្រូវរៀបចំឡើងនៅឆ្នាំទី៥នៃការអនុវត្តកម្មវិធី ដើម្បីពង្រឹងយន្តការអនុវត្ត។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវធ្វើការជាមួយក្រុមប្រឹក្សាជាតិគាំពារសង្គម ដើម្បីធ្វើការវាយតម្លៃលើកដំបូង និងការវាយតម្លៃពីផលប៉ះពាល់របស់កម្មវិធី។

# ជំពូកទី៣
# យន្តការនៃការអនុវត្តកម្មវិធី

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ គឺជាកម្មវិធីរបស់រាជរដ្ឋាភិបាល។ ការគ្រប់គ្រង ការដឹកនាំ និងការសម្របសម្រួលការអនុវត្តកម្មវិធីនឹងប្រើប្រាស់រចនាសម្ព័ន្ធស្ថាប័នដែលមានស្រាប់ ដើម្បីធានានិរន្តរភាព និងការលើកកម្ពស់ប្រសិទ្ធភាពការចំណាយទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

នៅថ្នាក់ជាតិ ក្រុមប្រឹក្សាជាតិគាំពារសង្គមមានតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួល និងការតម្រង់ទិសជាយុទ្ធសាស្ត្ររួមលើការងាររៀបចំគោលនយោបាយគាំពារសង្គម ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម ជាសេនាធិការឱ្យគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាស្ថាប័នទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធី ដោយសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងផែនការ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីទទួលខុសត្រូវ និងធានាដល់ការអនុវត្តកម្មវិធីឱ្យមានប្រសិទ្ធភាព។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធានក្រុមការងារ ដែលមានតំណាងមកពីក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថ ក្រសួងផែនការ និងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម ជាសមាជិកក្នុងក្រុមការងារ។

នៅថ្នាក់រាជធានី ខេត្ត រដ្ឋបាលរាជធានី ខេត្ត រៀបចំឱ្យមានយន្តការគាំទ្រការអនុវត្តកម្មវិធីនៅថ្នាក់រាជធានី ខេត្ត ដើម្បីសម្របសម្រួល និងពង្រឹងកិច្ចសហការរបស់មន្ទីរពាក់ព័ន្ធ រួមមាន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត មន្ទីរសុខាភិបាលរាជធានី ខេត្ត និងមន្ទីរផែនការរាជធានី ខេត្ត ក្នុងការអនុវត្តកម្មវិធី និងដោះស្រាយបញ្ហានានា។

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ជាស្ថាប័នទទួលខុសត្រូវលើការដឹកនាំ ការអនុវត្ត និងការតាមដានការអនុវត្តកម្មវិធី ដោយមានការគាំទ្រពីមន្ទីរសុខាភិបាលរាជធានី ខេត្ត ដើម្បីធានាការផ្តល់សេវាសុខភាពនៅមូលដ្ឋានសុខាភិបាលសាធារណៈប្រកបដោយគុណភាព និងដោះស្រាយបញ្ហា ក្នុងការអនុវត្តកម្មវិធី។

នៅថ្នាក់ឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដឹកនាំការអនុវត្តកម្មវិធី ដោយចាត់តាំងឱ្យមានអ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ដែលអាចប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ជាយន្តការគាំទ្រ និងដោះស្រាយបញ្ហានានាក្នុងការអនុវត្តកម្មវិធី។

មូលដ្ឋានសុខាភិបាលសាធារណៈមានតួនាទីបញ្ជាក់ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន និងសហការជាមួយឃុំ សង្កាត់ ដើម្បីដោះស្រាយបញ្ហានានា ដែលកើតមានឡើងក្នុងអំឡុងពេលនៃការអនុវត្តកម្មវិធី។

ស្ថាប័នបើកផ្តល់ សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការផ្តល់សេវាបើកសាច់ប្រាក់នៅទូទាំងប្រទេសសម្រាប់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។

## ៣.១. ក្រសួង ស្ថាប័នថ្នាក់ជាតិ

### ៣.១.១. ក្រុមប្រឹក្សាជាតិគាំពារសង្គម

ក្រុមប្រឹក្សាជាតិគាំពារសង្គម មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- សម្របសម្រួលកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធី
- ផ្តល់ការតម្រង់ទិសផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការអនុវត្តកម្មវិធី
- ពិនិត្យតាមដាន និងផ្តល់យោបល់លើវឌ្ឍនភាពនៃការអនុវត្តកម្មវិធី។

### ៣.១.២. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាស្ថាប័នទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងការអនុវត្តកម្មវិធី ដែលមាននាយកដ្ឋានសុខុមាលភាពសង្គមជាសេនាធិការក្នុងការអនុវត្តកម្មវិធី។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំគណៈកម្មការបច្ចេកទេស ដើម្បីអនុវត្តកម្មវិធី។ គណៈកម្មការបច្ចេកទេសមានក្រុមការងារប្រតិបត្តិកម្មវិធី ក្រុមការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយ ក្រុមការងារគ្រប់គ្រងប្រព័ន្ធព័ត៌មាន និងក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុ ។

#### ក). ក្រុមការងារប្រតិបត្តិកម្មវិធី

ក្រុមការងារប្រតិបត្តិកម្មវិធីទទួលខុសត្រូវលើសកម្មភាព ដូចខាងក្រោម ៖

- ត្រួតពិនិត្យមើលការអនុវត្តសកម្មភាពការងារប្រចាំថ្ងៃពាក់ព័ន្ធនឹងកម្មវិធី
- រៀបចំ និងដឹកនាំការប្រជុំប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំត្រីមាសស្តីពីវឌ្ឍនភាពរបស់កម្មវិធី
- គាំទ្រ និងផ្តល់ការណែនាំដល់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដើម្បីរៀបចំ និងអនុវត្តផែនការនៅថ្នាក់ខេត្ត
- ពិនិត្យតាមដានការចុះឈ្មោះ ការបញ្ជាក់ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព និងការបើកផ្តល់
- ធានាថា ទិន្នន័យប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានបានធ្វើបច្ចុប្បន្នភាពទាន់ពេលវេលាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- ធានាថាការឧបត្ថម្ភសាច់ប្រាក់ជូនអ្នកទទួលផលបានទាន់ពេលវេលា  បន្ទាប់ពីការផ្ទៀងផ្ទាត់ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព
- ពិនិត្យឡើងវិញនូវរបាយការណ៍តាមដានប្រចាំខែ ដើម្បីកែលម្អការអនុវត្តនៅក្នុងរាជធានី ខេត្ត
- ពិនិត្យសំណើរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដើម្បីផ្អាក ឬបញ្ឈប់ការបើកផ្តល់លើករណីក្លែងបន្លំរបស់អ្នកទទួលផល និងការចាកចេញពីកម្មវិធី
- រៀបចំរបាយការណ៍អំពីករណីនៃការរាយការណ៍ពីភាពមិនប្រក្រតី ឬការក្លែងបន្លំរបស់មន្ត្រីអនុវត្តកម្មវិធីជូនប្រធានគណៈកម្មការបច្ចេកទេស
- បង្កើត និងអនុវត្តក្របខ័ណ្ឌ និងផែនការពិនិត្យតាមដាន និងវាយតម្លៃកម្មវិធី

**ខ). ក្រុមការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយ**

ក្រុមការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- រៀបចំយុទ្ធសាស្ត្រ និងផែនការបណ្តុះបណ្តាល និងការអប់រំផ្សព្វផ្សាយ
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំសេចក្តីណែនាំលម្អិត និងឯកសារបណ្តុះបណ្តាល
- គាំទ្រមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដើម្បីផ្តល់វគ្គបណ្តុះបណ្តាល តាមការចាំបាច់
- តាមដានត្រួតពិនិត្យការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ
- រៀបចំរបាយកាណ៍លទ្ធផលបណ្តុះបណ្តាល និងការផ្សព្វផ្សាយ

**គ). ក្រុមការងារគ្រប់គ្រងប្រព័ន្ធព័ត៌មាន**

ក្រុមការងារគ្រប់គ្រងប្រព័ន្ធព័ត៌មាន មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ដឹកនាំ ត្រួតពិនិត្យ និងសម្របសម្រួលការរៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- រៀបចំ និងធ្វើតេស្តប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានរបស់កម្មវិធី
- ពិនិត្យមើលការតម្លើង  ទុកដាក់  និងគ្រប់គ្រងស៊ើវើ(Server)របស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ធ្វើសមាហរណកម្មជាមួយប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទិន្នន័យការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពអ្នកទទួលផល ឬប្រព័ន្ធផ្តល់សេវាបើកផ្តល់
- រៀបចំឯកសារបណ្តុះបណ្តាល និងចូលរួមផ្តល់ការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន  ដើម្បីធានាឱ្យមានការភ្ជាប់ទំនាក់ទំនង ជាមួយនឹងប្រព័ន្ធសំខាន់ៗ ដែលបានធ្វើសមាហរណកម្មនៅគ្រប់កម្រិត
- រក្សា តាមដាន និងធ្វើបច្ចុប្បន្នភាពស៊ើវើ(Server)ជាប្រចាំ ដើម្បីការពារមេរោគ និងហានិភ័យ
- គ្រប់គ្រងលើបូរណភាពទិន្នន័យ  ឯកជនភាព និងសន្តិសុខនៃទិន្នន័យផ្ទាល់ខ្លួន

- ធានាថា ឃុំ សង្កាត់ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត អាចចូលទៅប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- រៀបចំឱ្យមានការបម្រុងទុកទិន្នន័យរៀងរាល់ថ្ងៃ/សប្តាហ៍នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។

**ឃ). ក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុ**

ក្រុមការងារគ្រប់គ្រងហិរញ្ញវត្ថុមានតួនាទី និងការកិច្ច ដូចខាងក្រោម ៖

- សម្របសម្រួលលើការងារហិរញ្ញវត្ថុទាំងអស់របស់កម្មវិធី
- បំពេញតួនាទីជាអង្គភាពបង្គោលសម្រាប់ទំនាក់ទំនងជាមួយអ្នកផ្តល់សេវាបើកផ្តល់
- រៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់កម្មវិធី ដោយបញ្ចូលចំណាយប្រតិបត្តិការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំផែនការអនុវត្តថវិកាប្រចាំឆមាសសម្រាប់ការអនុវត្តកម្មវិធី ផ្ទៀងផ្ទាត់ និងសម្របសម្រួលការទូទាត់ជាប្រចាំខែ តាមរយៈការប្រមូល និងការវិភាគទិន្នន័យ ដែលបានពីប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន និងអ្នកផ្តល់សេវាបើកផ្តល់
- ពិនិត្យ និងកែសម្រួលលក្ខខណ្ឌសម្រាប់ការផ្តល់ថវិកា ផ្អែកតាមការផ្ទៀងផ្ទាត់ប្រចាំខែ និងការព្យាករណ៍ទុកអំពីការបែងចែកថវិកាទូទាត់
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុអំពីការទូទាត់ ភាពខុសគ្នា និងការផ្លាស់ប្តូរចំនួនដែលត្រូវទូទាត់ជារៀងរាល់ត្រីមាស។

## ៣.១.៣. ក្រសួងមហាផ្ទៃ

ក្រសួងមហាផ្ទៃ ជាស្ថាប័នគាំទ្រ និងសម្របសម្រួលការអនុវត្តកម្មវិធី។ ក្រសួងមហាផ្ទៃសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំយន្តការក្នុងការគាំទ្រការអនុវត្តកម្មវិធី។ ក្រសួងមហាផ្ទៃ មានតួនាទី និងការកិច្ច ដូចខាងក្រោម ៖

- រៀបចំ និងពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តតួនាទីរបស់អង្គភាពពាក់ព័ន្ធថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកម្មវិធី
- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងពាក់ព័ន្ធក្នុងការរៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពង្រឹងយន្តការដែលមានស្រាប់នៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការពិនិត្យតាមដាន និងគាំទ្រការអនុវត្តកម្មវិធី
- សហការក្នុងការពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហានានានៃការអនុវត្តកម្មវិធី។

## ៣.១.៤. ក្រសួងសុខាភិបាល

ក្រសួងសុខាភិបាល ដើរតួនាទីក្នុងការអនុវត្តកម្មវិធី ដូចខាងក្រោម ៖

- រៀបចំ និងពិនិត្យកែសម្រួលលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធី តាមការចាំបាច់
- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងពាក់ព័ន្ធក្នុងការរៀបចំ និងផ្តល់វគ្គបណ្តុះបណ្តាលពាក់ព័ន្ធការអនុវត្តកម្មវិធីដល់មូលដ្ឋានសុខាភិបាលសាធារណៈ
- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់ទិន្នន័យពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី
- ជំរុញមន្ទីរសុខាភិបាលរាជធានី ខេត្ត និងមូលដ្ឋានសុខាភិបាលសាធារណៈ ដើម្បីពង្រឹងការបញ្ជាក់នៃការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពរបស់អ្នកទទួលផល តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ចូលរួមពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធី។

## ៣.១.៥. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្របសម្រួលការផ្ទេរថវិកាសម្រាប់គាំទ្រការអនុវត្តកម្មវិធី។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទី និងការកិច្ច ដូចខាងក្រោម ៖

- ត្រួតពិនិត្យ ផ្តល់យោបល់ និងសម្រេចលើគម្រោងថវិកាសម្រាប់ការអនុវត្តកម្មវិធី
- រៀបចំថវិកាសម្រាប់ការបើកផ្តល់របបឧបត្ថម្ភជូនអ្នកទទួលផល
- ពិនិត្យរបាយការណ៍សកម្មភាពការងារ ហិរញ្ញវត្ថុ និងសមិទ្ធកម្មរបស់កម្មវិធី
- ចូលរួមពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធី។

## ៣.១.៦. ក្រសួងផែនការ

ក្រសួងផែនការ គាំទ្រ និងផ្តល់នូវទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ក្រសួងផែនការមានតួនាទី និងការកិច្ច ដូចខាងក្រោម ៖

- ផ្តល់ទិន្នន័យគ្រួសារក្រីក្រ ដែលមានសុពលភាពសម្រាប់ដាក់បញ្ចូលក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដើម្បីបញ្ចូលទិន្នន័យគ្រួសារក្រីក្រជាមួយនឹងកម្មវិធីប្រព័ន្ធគ្រប់គ្រងព័ត៌មាន
- សម្របសម្រួល និងលើកកម្ពស់កិច្ចសហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍនានា ដើម្បីគាំទ្រការអនុវត្តកម្មវិធី
- ចូលរួមកសាងសមត្ថភាព ពិនិត្យតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តកម្មវិធី។

## ៣.១.៧. ក្រុមការងារបច្ចេទេសអន្តរក្រសួង

ក្រុមការងារបច្ចេកទេសអន្តរក្រសួង មានសមាសភាព មកពី ៖

| | |
|---|---|
| ១. តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ២. តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៣. តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៤. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. តំណាងក្រសួងផែនការ | សមាជិក |
| ៦ .តំណាងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិគាំពារសង្គម | សមាជិក |
| ៧. តំណាងដៃគូអភិវឌ្ឍន៍ | សមាជិក |

ក្រុមការងារនេះ មានតួនាទី និងការកិច្ចមានដូចខាងក្រោម ៖

- សម្របសម្រួលការអនុវត្តកម្មវិធី
- សម្របសម្រួលក្នុងការអភិវឌ្ឍសមត្ថភាព និងការផ្សព្វផ្សាយដោយមានកិច្ចសហប្រតិបត្តិការពីក្រសួង ស្ថាប័នពាក់ព័ន្ធ
- គាំទ្រការផ្តល់ និងការធ្វើសមាហរណកម្មទិន្នន័យអត្តសញ្ញាណគ្រួសារក្រីក្ររបស់ក្រសួងផែនការ
- គាំទ្រការផ្ទេរទិន្នន័យ ការធ្វើសមាហរណកម្មទិន្នន័យ និងការបញ្ជាក់ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពរបស់អ្នកទទួលផលពីក្រសួងសុខាភិបាល
- ត្រួតពិនិត្យ និងបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាជាតិគាំពារសង្គម។

## ៣.២. អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ៣.២.១. រដ្ឋបាលរាជធានី ខេត្ត

រដ្ឋបាលរាជធានី ខេត្តរៀបចំយន្តការគាំទ្រការអនុវត្តកម្មវិធីនៅថ្នាក់រាជធានី ខេត្ត។ រដ្ឋបាលរាជធានី ខេត្តមានតួនាទី និងការកិច្ច ដូចខាងក្រោម ៖

- សម្របសម្រួលជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត មន្ទីរពាក់ព័ន្ធ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីគាំទ្រឃុំ សង្កាត់ ក្នុងការអនុវត្តកម្មវិធី
- សម្របសម្រួល និងចូលរួមផ្តល់វគ្គបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ដឹកនាំកិច្ចប្រជុំនៅថ្នាក់រាជធានី ខេត្ត ដើម្បីដោះស្រាយបញ្ហាក្នុងការអនុវត្តកម្មវិធី
- ពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ ដែលរៀបចំដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត។

## ៣.២.២. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ជាអង្គភាពអនុវត្តកម្មវិធី និងផ្តល់ការគាំទ្របច្ចេកទេសដល់ឃុំ សង្កាត់។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវបង្កើតក្រុមការងារ ដើម្បីអនុវត្តកម្មវិធី ដែលមានសមាសភាព ដូចខាងក្រោម ៖

ក. មន្ត្រីប្រតិបត្តិកម្មវិធី

ខ. មន្ត្រីបណ្តុះបណ្តាល និងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន

គ. មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ

សមាជិកក្រុមការងារនីមួយៗ មានតួនាទី និងភារកិច្ចជាក់លាក់របស់ខ្លួន។ សមាជិកក្រុមការងារនីមួយៗ អាចស្នើឱ្យមានមន្ត្រីគាំទ្រ តាមទំហំការងារចាំបាច់។

### ក). មន្ត្រីប្រតិបត្តិកម្មវិធី

មន្ត្រីប្រតិបត្តិកម្មវិធីមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធីប្រចាំថ្ងៃ
- រៀបចំផែនការសកម្មភាព និងថវិកា សម្រាប់ការអនុវត្តកម្មវិធី ដូចជា កសាងសមត្ថភាព ការផ្សព្វផ្សាយ ការពិនិត្យតាមដាន និងការដោះស្រាយបណ្តឹងតវ៉ា
- កសាងសមត្ថភាព និងគាំទ្របច្ចេកទេសដល់ឃុំ សង្កាត់ និងមូលដ្ឋានសុខាភិបាលសាធារណៈ ក្នុងការអនុវត្តកម្មវិធី
- ពិនិត្យតាមដានដំណើរការចុះឈ្មោះ និងបញ្ជាក់ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពរបស់អ្នកទទួលផល តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- សហការជាមួយរដ្ឋបាលរាជធានី ខេត្ត មន្ទីរសុខាភិបាល និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីដោះស្រាយបញ្ហានានាក្នុងការអនុវត្តកម្មវិធី
- សហការជាមួយស្ថាប័នបើកផ្តល់ ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការបើកផ្តល់
- ដឹកនាំកិច្ចប្រជុំប្រចាំសប្តាហ៍របស់ក្រុមការងាររបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ដើម្បីដោះស្រាយបញ្ហានានាក្នុងការអនុវត្តកម្មវិធី
- ចុះពិនិត្យតាមដានការអនុវត្តកម្មវិធីនៅឃុំ សង្កាត់ និងមូលដ្ឋានសុខាភិបាលសាធារណៈ និងសហគមន៍
- គាំទ្រ និងដោះស្រាយបណ្តឹងតវ៉ា និងការក្លែងបន្លំរបស់អ្នកទទួលផល ដែលស្នើឡើងដោយឃុំ សង្កាត់
- បញ្ជូនករណីអំពីការប្រព្រឹត្តមិនត្រឹមត្រូវរបស់មន្ត្រីពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីទៅមន្ទីរសាមី ឬគណៈកម្មការបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីដោះស្រាយ
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំ និងផ្ញើជូនរដ្ឋបាលរាជធានី ខេត្ត និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

### ខ). មន្ត្រីបណ្តុះបណ្តាល និងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន

មន្ត្រីបណ្តុះបណ្តាល និងគ្រប់គ្រងប្រព័ន្ធព័ត៌មាន មានតួនាទី និងការកិច្ច ដូចខាងក្រោម ៖

- រៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ
- សហការជាមួយរដ្ឋបាលរាជធានី ខេត្ត និងមន្ទីរពាក់ព័ន្ធ ក្នុងការផ្តល់ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយ
- គាំទ្រឃុំ សង្កាត់ និងមូលដ្ឋានសុខាភិបាលសាធារណៈ ក្នុងការអប់រំផ្សព្វផ្សាយ
- ពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពបណ្តុះបណ្តាល និងអប់រំផ្សព្វផ្សាយ
- ដោះស្រាយបញ្ហាជាប្រចាំអំពីការប្រើប្រាស់ ឬការអាក់រអួលរបស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ពិនិត្យគុណភាពទិន្នន័យដែលបានបញ្ជូល និងផ្តល់ព័ត៌មានត្រឡប់ដល់ឃុំ សង្កាត់ និងមូលដ្ឋានសុខាភិបាលសាធារណៈ
- បូកសរុបរបាយការណ៍អំពីសកម្មភាពវគ្គបណ្តុះបណ្តាល និងអប់រំផ្សព្វផ្សាយ។

### គ). មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ

មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ មានតួនាទី និងការកិច្ច ដូចខាងក្រោម ៖

- រៀបចំផែនការថវិកាប្រចាំឆ្នាំ ប៉ាន់ប្រមាណតម្រូវការថវិកាប្រចាំត្រីមាសសម្រាប់ប្រតិបត្តិការ និងការបើកផ្តល់ដល់អ្នកទទួលផល
- ផ្ទៀងផ្ទាត់ការបើកផ្តល់ជារៀងរាល់ខែ និងកែសម្រួលតម្រូវការថវិកាសម្រាប់ការបើកផ្តល់រៀងរាល់៣ខែបន្ទាប់
- រៀបចំរបាយការណ៍ផ្ទៀងផ្ទាត់ និងរបាយការណ៍ហិរញ្ញវត្ថុ។

## ៣.២.៣. មន្ទីរសុខាភិបាលរាជធានី ខេត្ត

មន្ទីរសុខាភិបាលរាជធានី ខេត្ត គាំទ្រ និងសម្របសម្រួលជាមួយមូលដ្ឋានសុខាភិបាលសាធារណៈ ក្នុងការផ្តល់សេវាសុខភាព ការបញ្ជាក់ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាពរបស់អ្នកទទួលផល ពង្រឹងសមត្ថភាព និងដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងវិស័យសុខាភិបាល។

## ៣.២.៤. មូលដ្ឋានសុខាភិបាលសាធារណៈ

មូលដ្ឋានសុខាភិបាលសាធារណៈ មានតួនាទី និងការកិច្ច ដូចខាងក្រោម ៖

- ផ្តល់សេវាពិនិត្យផ្ទៃពោះមុនពេលសម្រាល សម្រាល ពិនិត្យក្រោយសម្រាល និងផ្តល់ថ្នាំបង្ការដល់កុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រ ដើម្បីមានសៀវភៅសុខភាពមាតា ឬប័ណ្ណសុខភាពកុមារយកមកចុះឈ្មោះក្នុងកម្មវិធីលើកដំបូង នៅឃុំ សង្កាត់
- បញ្ជាក់ការអនុវត្តលក្ខខណ្ឌពិនិត្យផ្ទៃពោះមុនសម្រាល សម្រាល ពិនិត្យក្រោយសម្រាល និងផ្តល់ថ្នាំបង្ការដល់កុមារ តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន

- ធ្វើបច្ចុប្បន្នភាពការស្លាប់របស់កូន ឬមាតា ដែលជាអ្នកទទួលផលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ក្នុងករណីស្លាប់នៅមូលដ្ឋានសុខាភិបាលសាធារណៈ
- កត់ត្រា និងរាយការណ៍នៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានអំពីការលួតកូន និងរំលូតកូន
- សហការជាមួយនឹងឃុំ សង្កាត់ ក្នុងការដោះស្រាយបញ្ហា និងបណ្តឹងតវ៉ា ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសុខាភិបាល។

## ៣.២.៥. រដ្ឋបាលឃុំ សង្កាត់

នៅថ្នាក់ឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ដឹកនាំការអនុវត្តកម្មវិធី ដោយចាត់តាំងឱ្យមានអ្នកទទួលបន្ទុកកម្មវិធីនៅឃុំ សង្កាត់ ដែលអាចប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន។ ឃុំ សង្កាត់មានតួនាទី និង ភារកិច្ច ដូចខាងក្រោម ៖

- អប់រំផ្សព្វផ្សាយអំពីកម្មវិធីដល់សហគមន៍
- ណែនាំអ្នកទទួលផលអំពីនីតិវិធីនៃការចុះឈ្មោះ ការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព ការបើកផ្តល់ ការដោះស្រាយបណ្តឹងតវ៉ា និងការចាកចេញពីកម្មវិធី
- ចុះឈ្មោះ និងអនុម័តស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ក្នុងគ្រួសារក្រីក្រចូលក្នុងកម្មវិធី
- ដោះស្រាយបណ្តឹងតវ៉ា និងការក្លែងបន្លំព័ត៌មានរបស់អ្នកទទួលផល ដោយកត់ត្រាករណីទាំងនោះទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- បញ្ជូនពាក្យបណ្តឹងតវ៉ា ដែលមិនអាចដោះស្រាយរួចទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ធ្វើបច្ចុប្បន្នភាពការស្លាប់របស់កូន ឬមាតា ដែលជាអ្នកទទួលផលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន
- ពិនិត្យតាមដានការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព តាមប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន ដើម្បីកំណត់រកអ្នកទទួលផល ដែលពុំបានអនុវត្តតាមលក្ខខណ្ឌពិនិត្យសុខភាព
- រៀបចំផែនការ និងអនុវត្តសកម្មភាពផ្សព្វផ្សាយ និងជំរុញស្ត្រីមានផ្ទៃពោះ និងកុមារទៅទទួលសេវាថែទាំសុខភាព
- ពង្រឹងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីចូលរួមអនុវត្តកម្មវិធី
- បញ្ចូលរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីចូលទៅក្នុងរបាយការណ៍បូកសរុបលទ្ធផលការងារឃុំ សង្កាត់
- ដាក់បញ្ចូលសកម្មភាពគាំទ្រការអនុវត្តកម្មវិធីទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់។

## ៣.៣. ស្ថាប័នបើកផ្តល់

ការឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំត្រូវបានបើកផ្តល់តាមគណនីធនាគាររបស់អ្នកទទួលផល។ ស្ថាប័នបើកផ្តល់ ត្រូវមានភ្នាក់ងារបើកផ្តល់នៅតាមឃុំ សង្កាត់។ ស្ថាប័នបើកផ្តល់ មានតួនាទី ភារកិច្ចដូចខាងក្រោម ៖

- សហការក្នុងការធ្វើសមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានរបស់កម្មវិធី
- ផ្តល់ប័ណ្ណគណនីធនាគារដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បើកគណនីធនាគារដល់អ្នកទទួលផល
- ណែនាំ និងផ្តល់ខិតប័ណ្ណអំពីការប្រើប្រាស់ប័ណ្ណគណនីធនាគារ និងទីតាំងបើកផ្តល់
- ដាក់ឱ្យប្រើប្រាស់ទូរស័ព្ទទាន់ហេតុការណ៍សម្រាប់កម្មវិធី ដើម្បីដោះស្រាយបញ្ហា
- ណែនាំភ្នាក់ងារបើកផ្តល់អំពីនីតិវិធីបើកប្រាក់ដល់អ្នកទទួលផលនៃកម្មវិធី
- សហការក្នុងការដោះស្រាយបញ្ហាប្រឈមនានា
- ផ្ទេរសាច់ប្រាក់ចូលទៅក្នុងគណនីធនាគាររបស់អ្នកទទួលផលភ្លាមៗបន្ទាប់ពីទទួលបានការអនុម័ត
- ជូនដំណឹងដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាបន្ទាន់ ករណីមានការពន្យារពេល
- ផ្តល់របាយការណ៍អំពីការផ្ទេរសាច់ប្រាក់ដែលជោគជ័យ និងមិនជោគជ័យ។ ករណីការផ្ទេរសាច់ប្រាក់មិនបានជោគជ័យត្រូវបញ្ជាក់ពីមូលហេតុ
- ផ្តល់របាយការណ៍នៃការដកប្រាក់ចេញពីគណនីធនាគាររបស់អ្នកទទួលផល
- គាំទ្រដល់ដំណើរការផ្ទៀងផ្ទាត់ ការទូទាត់ ដោយផ្តល់ទិន្នន័យដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ឧបសម្ព័ន្ធទី១. ការពន្យល់ពាក្យគន្លឹះ

| | |
|---|---|
| **១. ប័ណ្ណសមធម៌** | សំដៅដល់ប័ណ្ណដែលចេញដោយក្រសួងផែនការ តាមរយៈការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ តាមជុំប្រមូលទិន្នន័យ ឬតាមការស្នើសុំ។ |
| **២. ប័ណ្ណអាទិភាព** | សំដៅដល់ប័ណ្ណដែលចេញដោយមន្ទីរពេទ្យសម្រាប់ទទួលសេវាសុខភាពសាធារណៈ និងប័ណ្ណដែលចេញដោយមណ្ឌលសុខភាព សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកូនអាយុក្រោម២ឆ្នាំ។ |
| **៣. សៀវភៅសុខភាពមាតា** | សំដៅដល់សៀវភៅដែលចេញដោយក្រសួងសុខាភិបាលសម្រាប់ជាកំណត់ហេតុតាមដានពេលមានផ្ទៃពោះ ពេលឈឺពោះសម្រាល សម្រាលកូន រហូតដល់ក្រោយសម្រាល ដើម្បីរកឱ្យឃើញនូវសញ្ញាគ្រោះថ្នាក់ និងធ្វើការថែទាំម្តាយ និងទារកឱ្យមានប្រសិទ្ធភាព។ |
| **៤. ប័ណ្ណសុខភាពកុមារ** | សំដៅដល់ប័ណ្ណសុខភាពកុមារ ឬប័ណ្ណសុខភាពកុមារី ដែលចេញដោយក្រសួងសុខាភិបាលសម្រាប់ជាកំណត់ហេតុតាមដានការលូតលាស់របស់ទារក/ទារិកា កុមារ/កុមារី អាហារូបត្ថម្ភ និងការផ្តល់ថ្នាំបង្ការ។ |
| **៥. ស្ថាប័នបើកផ្តល់** | សំដៅដល់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុដែលមានច្បាប់អនុញ្ញាត ដែលបានចុះអនុស្សរណៈយោគយល់ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា ដើម្បីផ្តល់សេវាផ្ទេរសាច់ប្រាក់ដល់អ្នកទទួលផលរបស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ។ |
| **៦. ភ្នាក់ងារបើកផ្តល់** | សំដៅដល់ភ្នាក់ងាររបស់ធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុដែលបានចុះអនុស្សរណៈ យោគយល់ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បី ផ្តល់សេវាបើកសាច់ប្រាក់ដល់អ្នកទទួលផលរបស់កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ នៅតាមឃុំសង្កាត់។ |
| **៧. ប័ណ្ណគណនីធនាគារ** | សំដៅដល់ប័ណ្ណបើកប្រាក់របស់អ្នកទទួលផលដែលចេញដោយធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ ដែលផ្តល់សេវាផ្ទេរសាច់ប្រាក់នៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។ |
| **៨. មូលដ្ឋានសុខាភិបាលសាធារណៈ** | សំដៅដល់មន្ទីរពេទ្យបង្អែកដែលផ្តល់សេវាសំណុំសកម្មភាពបង្ក្រប់ និងមណ្ឌលសុខភាពដែលផ្តល់សំណុំសកម្មភាពអប្បបរមា។ |
| **៩. ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មាន** | សំដៅដល់កម្មវិធីក្នុងតាប្លេត(Tablet) ឬកុំព្យូទ័រសម្រាប់ការគ្រប់គ្រងព័ត៌មានរបស់កម្មវិធី តាមរយៈការកត់ត្រា ការបញ្ចូល ការបញ្ជូន ការទុកដាក់ និងការរាយការណ៍។ |
| **១០. ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ** | សំដៅដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំនៃគ្រួសារក្រីក្រ ដែលមានប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព។ |

# ឧបសម្ព័ន្ធទី២. សង្ខេបដំណើរការកម្មវិធី

## កំនួសបំព្រួញទី១. ការចុះឈ្មោះ និងការបើកផ្តល់លើកដំបូង



## គំនូសបំព្រួញទី២. ការអនុវត្តលក្ខខណ្ឌ និងការបើកផ្តល់



## គំនូសបំព្រួញទី៣. ការតាមដានការអនុវត្តលក្ខខណ្ឌពិនិត្យសុខភាព



# កំនូសបំព្រួញទី៤. ការដោះស្រាយវិវាទ និងបណ្តឹងរបស់អ្នកទទួលផល



## កំនួសបំព្រួញទី៥. ការដោះស្រាយករណីក្លែងបន្លំរបស់អ្នកទទួលផល



## គំនូសបំព្រួញទី៦. ការដោះស្រាយករណីកំហុសប្រព្រឹត្តដោយមន្ត្រីកម្មវិធី



# គំនូសបំព្រួញទី៧. ការចាកចេញពីកម្មវិធី




ការស្លាប់កូនពេលកើត
បុគ្គលិកមូលដ្ឋានសុខាភិបាលសាធារណៈ បញ្ជាក់ការស្លាប់កូនក្នុង MIS ទៅក្រសួងស.អ.យ
ក្រសួង ស.អ.យ.បញ្ជូនព័ត៌មានទៅស្តាប់ធនបើកផ្តល់ ដើម្បីផ្ទេរសាច់ប្រាក់ចូលគណនីអ្នកទទួលផល
អ្នកទទួលផលបើកប្រាក់ពីភ្នាក់ងារបើកប្រាក់
អ្នកទទួលផលទៅពិនិត្យសុខភាពក្រោយសម្រាលលើកទី១
បុគ្គលិកសុខាភិបាលពិនិត្យសុខភាពក្រោយសម្រាលលើកទី១ និងបញ្ជាក់ការអនុវត្តលក្ខខណ្ឌក្នុងMISទៅក្រសួង ស.អ.យ
ក្រសួង ស.អ.យ.បញ្ជូនព័ត៌មានទៅស្តាប់ធនបើកផ្តល់ ដើម្បីផ្ទេរសាច់ប្រាក់ចូលគណនីអ្នកទទួលផល
អ្នកទទួលផលបើកប្រាក់ពីភ្នាក់ងារបើកប្រាក់
អ្នកទទួលផលទៅពិនិត្យសុខភាពក្រោយសម្រាលលើកទី២
បុគ្គលិកសុខាភិបាលពិនិត្យសុខភាពក្រោយសម្រាលលើកទី២ និងបញ្ជាក់ការអនុវត្តលក្ខខណ្ឌក្នុងMISទៅក្រសួង ស.អ.យ
ក្រសួង ស.អ.យ.បញ្ជូនព័ត៌មានទៅស្តាប់ធនបើកផ្តល់ ដើម្បីផ្ទេរសាច់ប្រាក់ចូលគណនីអ្នកទទួលផល
អ្នកទទួលផលបើកប្រាក់ពីភ្នាក់ងារបើកប្រាក់
អ្នកទទួលផលទៅពិនិត្យសុខភាពក្រោយសម្រាលលើកទី៣
បុគ្គលិកសុខាភិបាលពិនិត្យសុខភាពក្រោយសម្រាលលើកទី៣ និងបញ្ជាក់ការអនុវត្តលក្ខខណ្ឌក្នុងMISទៅក្រសួង ស.អ.យ
ក្រសួង ស.អ.យ.បញ្ជូនព័ត៌មានទៅស្តាប់ធនបើកផ្តល់ ដើម្បីផ្ទេរសាច់ប្រាក់ចូលគណនីអ្នកទទួលផល
អ្នកទទួលផលបើកប្រាក់ពីភ្នាក់ងារបើកប្រាក់
អ្នកទទួលផលត្រូវចាកចេញពីកម្មវិធីដោយស្វ័យប្រវត្តិ


ការស្លាប់ម្តាយក្នុងពេលសម្រាល
បុគ្គលិកមូលដ្ឋានសុខាភិបាលសាធាណៈ បច្ចុប្បន្នភាពអំពីការស្លាប់ម្តាយពេលសម្រាល រួចបញ្ជូនមក្រសួងតាមMIS
ក្រសួង ស.អ.យ.បញ្ជូនព័ត៌មានទៅស្ថាប័នបើកផ្តល់ ដើម្បីផ្ទេរសាច់ប្រាក់ចូលគណនីអ្នកទទួលផល
កូនកើតមក ត្រូវធ្វើការចុះឈ្មោះនៅឃុំ សង្កាត់ដោយដាក់អាណាព្យាបាលកុមារថ្មី
ឃុំ សង្កាត់ត្រូវធ្វើបច្ចុប្បន្នភាពអាណាព្យាបាលកុមារ ក្នុង MIS
កុមារអ្នកទទួលផលទទួលបានការឧបត្ថម្ភសាច់ប្រាក់ជាអតិបរិមា ១០លើក នៅពេលមកពិនិត្យសុខភាព